# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## <u>សេចក្តីប្រកាសព័ត៌មាន</u>

ថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ២០២០

## អូស្ត្រាលីអបអរជំហានរឹងមាំរបស់កម្ពុជាលើឧក្រិដ្ឋកម្មឆ្លងដែន

អូស្ត្រាលីសូមអបអរសាទរកម្ពុជា ក្នុងការប្រកាសជាប្រវត្តិសាស្ត្រ ដាក់ឱ្យប្រើប្រាស់ច្បាប់ប្រឆាំងការលាងសម្អាតប្រាក់ និងការរឹកសាយភាយហិរញ្ញប្បទានភេរវកម្ម ដែលបានទទួលព្រះរាជក្រមប្រកាសឱ្យប្រើប្រាស់ និងមានសុពលភាពពីពេលនេះតទៅ។

ឯកឧត្តម Pablo Kang ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំនៅកម្ពុជា បានមានប្រសាសន៍ថាៈ "ការអនុវត្តច្បាប់ការលាងសម្អាតប្រាក់ និងប្រឆាំងហិរញ្ញប្បទានភេរវកម្ម បង្ហាញពីជំហ៊ានយ៉ាងសំខាន់របស់រដ្ឋាភិបាល និង ប្រជាជនកម្ពុជា។"

"វាក៏ជាពេលវេលាប្រកបដោយមោទនភាព និងជាប្រវត្តិសាស្ត្រ នៅក្នុងទំនាក់ទំនងទ្វេភាគីរវាងប្រទេសយើងទាំងពីរ ព្រោះយើងបានធ្វើការក្នុងភាពជាដៃគូ ដើម្បីពង្រឹងច្បាប់ទាំងនេះជាមួយគ្នា។"

ចាប់ពីឆ្នាំ២០១៨ មក ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ របស់អូស្ត្រាលី បានធ្វើការយ៉ាងជិតស្និទ្ធជាមួយមន្ត្រីរដ្ឋាភិបាលកម្ពុជា ដើម្បីកែលំអរ ក្របខណ្ឌច្បាប់ ក្នុងការដោះស្រាយឧក្រិដ្ឋកម្មឆ្លងដែន រួមមានការប្រឹក្សាបច្ចេកទេសក្នុងការពង្រាងច្បាប់ទាំងនេះ។

ក្នុងនាមជាសមាជិកក្រុមអាស៊ី ប៉ាស៊ីហ្វិក ធ្វើការលើការលាងសម្អាតប្រាក់ កម្ពុជាប្តេជ្ញាក្នុងការបង្កើតក្របខណ្ឌច្បាប់ ប្រឆាំងនឹងការរឹកសាយភាយហិរញ្ញប្បទានភេរវកម្ម។

ក្រោមច្បាប់ថ្មីនេះ កម្ពុជានឹងមានសមត្ថភាព អនុវត្តទណ្ឌកម្មហិរញ្ញប្បទានគោលដៅ ដើម្បីដកហូតទ្រព្យអ្នកផ្តល់ការរឹកសាយភាយហិរញ្ញប្បទានភេរវកម្ម ដែលនឹងការពារប្រជាជនកម្ពុជា ពីការគំរាមកំហែងរបស់អាវុធប្រល័យលោក។

កម្ពុជានឹងស្ថិតនៅទីតាំងកាន់តែប្រសើរ ក្នុងការធានាថាឧក្រិដ្ឋជនទាំងអស់ មិនអាចគិតជុតពីការកាត់ទោស ដោយសារតែ ភស្តុតាងឬ ដំណើរការឧក្រិដ្ឋកម្មរបស់គេ កើតឡើងនៅប្រទេសផ្សេងៗនោះទេ។ វានឹងបង្កើតឱ្យមានសហគមន៍កាន់តែមានសុវត្ថិភាព និងតំបន់កាន់តែមានសន្តិសុខ។

ឯកអគ្គរាជទូត Kang បានមានប្រសាសន៍ថា៖ "ក្នុងនាមជាដៃគូទ្វេភាគីយូរអង្វែង និងគួរឱ្យទុកចិត្ត ខ្ញុំមានសេចក្តីរីករាយ ដែលអូស្ត្រាលី អាចធ្វើការជាមួយសហភាគីកម្ពុជារបស់យើង ក្នុងការបង្កើតក្របខណ្ឌច្បាប់សំខាន់ៗទាំងនេះ។"

លោក Dan Mossop លេខារង ផ្នែកគោលនយោបាយឧក្រិដ្ឋកម្មឆ្លងដែន របស់ក្រសួងមហាផ្ទៃអូស្ត្រាលី បានមានប្រសាសន៍ថា៖ "យើងរំពឹងបន្តការចូលរួមរបស់យើងជាមួយកម្ពុជា លើបញ្ហាឧក្រិដ្ឋកម្មឆ្លងដែន ដើម្បីលើកកំពស់សន្តិសុខ និងស្ថេរភាព នៅក្នុងតំបន់ឱ្យកាន់តែប្រសើរ។"

**ទំនាក់ទំនងព័ត៌មាន៖** Australian.Embassy.Cambodia@dfat.gov.au